**សហភាពអឺរ៉ុប**

ទីក្រុងប្រាហ្សុលស៍ ២៣ តុលា គ.ស.២០១១

A ៤២៦/១១

# សេចក្តីថ្លែងការណ៍ដោយអ្នកនាំពាក្យនៃតំណាងជាន់ខ្ពស់សហភាពអឺរ៉ុប អ្នកស្រី ខាថារីន អាសស្តិន ស្តីពី ទិវាសន្តិភាពទីក្រុងប៉ារីស គម្រប់ខួប ២០ឆ្នាំ ១៩៩១ ដែលនាំមកនូវដំណើរសន្តិភាពនៅកម្ពុជា

អ្នកនាំពាក្យរបស់អ្នកស្រី ខាថារីន អាសស្តិន តំណាងជាន់ខ្ពស់នៃសហភាពអឺរ៉ុបទទួលបន្ទុកកិច្ចការបរទេសនិងសន្តិសុខ ហើយនិងជាអនុប្រធានិកាស្នងការ បានបញ្ចេញសេចក្តីថ្លែងការណ៍នៅថ្ងៃនេះដូចតទៅ:

“តំណាងជាន់ខ្ពស់ អ្នកស្រី ខាថារីន អាសស្តិន យកឱកាសនៃទិវាសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ ដើម្បីសម្តែងនូវសេចក្តីកោតសរសើរដល់ប្រជាពលរដ្ឋកម្ពុជាចំពោះការរីកចម្រើនផ្នែកនយោបាយ សង្គមកិច្ច និង សេដ្ឋកិច្ចគួរឱ្យកត់សម្គាល់អស់រយៈពេលជាង ២០ឆ្នាំចុងក្រោយនេះ ។

សហភាពអឺរ៉ុបនៅតែប្តេជ្ញាចិត្តលើដំណើរការផ្លាស់ប្តូរនៃកម្ពុជា និងនឹងបន្តគាំទ្រប្រជាពលរដ្ឋខ្មែរទាំងអស់ ដែលកំពុងដំណើរការឆ្ពោះទៅរកការអភិវឌ្ឍន៍និងប្រជាធិបតេយ្យសម្រាប់ពេលយូរអង្វែងនៅក្នុងប្រទេស ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ECCC ពិសេស មានតួនាទីចាំបាច់ មិនមែនត្រឹមតែធានាក្នុងការទទួលខុសត្រូវចំពោះជនរងគ្រោះនៃរបបខ្មែរក្រហមប៉ុណ្ណោះទេ ក៏ប៉ុន្តែធានាក្នុងការអភិវឌ្ឍន៍សមត្ថភាពតុលាការ និងការលើកស្ទួយការផ្សះផ្សាជាតិសម្រាប់ពេលយូរអង្វែងនៅកម្ពុជា ។

កម្ពុជាបានដំណើរការយ៉ាងឆ្ងាយតាំងពីឆ្នាំ១៩៩១មក និងអ្នកតំណាងជាន់ខ្ពស់ទាមទាររដ្ឋាភិបាលធានាការគោរពចំពោះនិងការប្រតិបត្តិតាមសិទ្ធិមនុស្សនិងសេរីភាពជាគ្រឹះមូលដ្ឋាន និងបញ្ចប់ដំណើរការផ្លាស់ប្តូរនិងសន្តិភាពឱ្យបានរួចរាល់ជាស្ថាពរ ដែលបានចាប់ផ្តើមដំណើរការក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីស ។”

ការបកប្រែក្រៅផ្លូវការ ភាសាដើមអង់គ្លេស
kkcpressoffice@yahoo.com

---

## សេចក្តីប្រកាសព័ត៌មាន


សម្រាប់ព័ត៌មានបន្ថែម

លោក Michael Mann +៣២ ៤៩៨ ៩៩៩ ៧៨០, +៣២ ២ ២៩៩ ៩៧ ៨០ Michael.Mann@eeas.europa.eu

អ្នកស្រី Maja Kocijancic +៣២ ៤៩៨ ៩៨៤ ៤២៥, +៣២ ២ ២៩៨ ៦៥ ៧០ Maja.Kocijancic@ee.europa.eu

COMM-SPP-HRVP-ASHTON@ee.europa.eu
www.eeas.europa.eu